ចំណងជើង: ការជំរុញនិរន្តរភាព៖ តម្រូវការសម្រាប់ទស្សនវិស័យក្នុងតំបន់

ចំណងជើង: បទពិសោធន៍ និងសមិទ្ធិផលរយៈពេល ១០ ឆ្នាំនៃការលើកកម្ពស់ការផ្លាស់ប្តូរប្រកបដោយនិរន្តរភាពតាមរយៈសកម្មភាពក្នុងតំបន់

របៀបវារៈថ្ងៃពុធ ទី២៦ ខែ កុម្ភៈ

| | |
|---|---|
| ០៨:៣០-១២:០០ | រយៈពេល១០ឆ្នាំនៃការលើកកម្ពស់ទស្សនវិស័យក្នុងតំបន់<br><br>ចូលរួមជាមួយយើង! គម្រោង GIZ FABRIC នឹងចែករំលែកអំពីចំណុចសំខាន់ៗមួយចំនួនបន្ទាប់ពីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ក្នុងតំបន់រយៈពេល ១០ ឆ្នាំ នៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរដើម្បីការប្រកួតប្រជែងដែលប្រកបដោយយុត្តិធម៌និងការគោរពចំពោះមនុស្សនិងបរិស្ថាន។ |
| ០៨:៣០ – ០៩:០០ | ការអញ្ជើញចុះឈ្មោះនិងពិសារកាហ្វេពេលព្រឹក |
| ០៩:០០– ០៩:៣០ | បើកកម្មវិធី |
| | ស្ថានទូតអាល្លឺម៉ង់ប្រចាំកម្ពុជា និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ០៩:៣០– ១០:០០ | ដាក់បញ្ចូលសម្លេងក្នុងតំបន់ទៅក្នុងឧស្សាហកម្មសកល |
| | គម្រោង GIZ FABRIC នឹងចែករំលែកអំពីចំណុចសំខាន់ៗមួយចំនួនបន្ទាប់ពីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ក្នុងតំបន់រយៈពេល ១០ ឆ្នាំ នៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរដើម្បីការប្រកួតប្រជែងដែលប្រកបដោយយុត្តិធម៌និងការគោរពចំពោះមនុស្សនិងបរិស្ថាន។ |
| ១០:០០-១១:០០ | សម្លឹងទៅមុខ |
| | នៅក្នុងវគ្គអន្តរកម្មនេះ ភាគីពាក់ព័ន្ធមកពីក្នុងឧស្សាហកម្មចែករំលែកអំពីការវិវត្តន៍របស់ឧស្សាហកម្មក្នុងតំបន់ ហើយពិភាក្សារួមគ្នាជាមួយអ្នកចូលរួមអំពីដំណើរការវិវត្តន៍របស់ឧស្សាហកម្មវាយនភណ្ឌនេះ។ |
| ១១:០០– ១១:៣០ | ការបង្ហាញម៉ូដប្រកបដោយនិរន្តរភាព |

| | |
|---|---|
| | ការផ្គត់ផ្គង់ ការផលិត និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព គឺជាដំណើរការដ៏ស្មុគស្មាញមួយ ប៉ុន្តែអ្នកស្រាវជ្រាវមួយចំនួនមកពីក្នុងតំបន់នឹងគូសបញ្ជាក់បង្ហាញពីដំណោះស្រាយដែលពួកគេបានរកឃើញ។ |
| ១២:០០ | បិទកម្មវិធី |
| ពេលថ្ងៃ | ទស្សនៈកិច្ចរោងចក្រ-សម្រាប់ភ្ញៀវដែលទទួលបានការអញ្ជើញ |
| | ភ្ញៀវដែលត្រូវបានអញ្ជើញនឹងទៅទស្សនៈកិច្ចរោងចក្រនៅកម្ពុជាចំនួនពីរ ដើម្បីស្វែងយល់បន្ថែមអំពីផលិតកម្មក្នុងស្រុក។ សម្រាប់ព័ត៌មានលម្អិតនឹងជូនដំណឹងតាមរយៈអ៊ីមែលនៅខែមករា។ |

របៀបវារៈថ្ងៃព្រហស្បត្តិ៍ ទី២៧ ខែ កុម្ភៈ – ផ្នែក ក

| | |
|---|---|
| ០៩:០០– ០៥:៣០ | ការពង្រីកសំឡេងរបស់កម្មករក្នុងឧស្សាហកម្មវាយនភណ្ឌ កាត់ដេរ និងស្បែកជើងនៅអាស៊ី<br>តាមរយៈសុន្ទរកថា កិច្ចពិភាក្សា និងជាពិសេសវគ្គអន្តរកម្ម អ្នកចូលរួមនឹងស្វែងយល់ពីយុទ្ធសាស្ត្រដើម្បីពង្រីកសំឡេងរបស់កម្មករ ដំណោះស្រាយលើបញ្ហាប្រឈម និងការអនុវត្តន៍ការដោះស្រាយជាក់ស្តែង ដើម្បីកសាងឧស្សាហកម្មដែលប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព។ ការពិភាក្សារួមគ្នានឹងបង្ហាញពីឧបករណ៍ច្នៃប្រឌិត គំនិតផ្តួចផ្តើមមូលដ្ឋាន និងភាពជាដៃគូដែលផ្តល់សិទ្ធិអំណាចដល់កម្មករ និងជំរុញកំណើនឧស្សាហកម្មសមធម៌។ |
| ០៩:០០– ០៩:៣០ | ការអញ្ជើញចុះឈ្មោះ |
| ០៩:៣០– ០៩:៤៥ | បើកកិច្ចប្រជុំពេញអង្គ |

| | |
|---|---|
| ០៩:៤៥– ១០:១០ | សុន្ទរកថាស្តីពីការពង្រឹងសំឡេងកម្មករសម្រាប់ឧស្សាហកម្មប្រកបដោយបរិយាប័ណ្ណ និងនិរន្តរភាព |
| | វគ្គនេះនឹងពិភាក្សាអំពីសារៈសំខាន់នៃការពង្រីកសំឡេងរបស់កម្មករ ជាពិសេសកម្មករជាស្ត្រីនៅក្នុងឧស្សាហកម្មនេះ។ ការពិភាក្សានឹងស្វែងយល់ពីឧបសគ្គចម្បងចំពោះការចូលរួមរបស់ពួកគេ។ ការពិភាក្សានឹងគូសបង្ហាញអំពីយុទ្ធសាស្ត្រក្នុងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងជំរុញកំណើនឧស្សាហកម្មប្រកបដោយសមធម៌។ |
| ១០:១០– ១០:៤០ | កិច្ចពិភាក្សាស្តីពីការលើកកម្ពស់សមភាពយេនឌ័រ៖ ឧបករណ៍វិភាគយេនឌ័រ |
| | វគ្គនេះនឹងណែនាំអំពីឧបករណ៍វិភាគយេនឌ័ររបស់ GIZ ដែលជាឧបករណ៍សម្រាប់ការអនុវត្តជាក់ស្តែងដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងដំណើរការគំនិតផ្តួចផ្តើមក្នុងតំបន់ផ្សេងៗគ្នា។ កិច្ចពិភាក្សានឹងណែនាំពីចំណុចសំខាន់ៗ ដូចជារបៀបចង្អុលបង្ហាញគម្លាតយេនឌ័រ ឬរបៀបបង្កើតយុទ្ធសាស្ត្រដែលអាចធ្វើសកម្មភាពបាន ដើម្បីលើកកម្ពស់បរិយាប័ណ្ណ និងសមធម៌ ជាមួយនឹងគោលដៅពង្រឹងសំឡេងរបស់កម្មករស្ត្រីនៅក្នុងឧស្សាហកម្មវាយនភណ្ឌ។ |
| ១០:៤០- ១១:០០ | សម្រាកអាហារសម្រន់ |
| ១១:០០- ១២:៤៥ | កិច្ចពិភាក្សាអំពីការអនុវត្តល្អក្នុងការចូលរួមរបស់កម្មករ |
| | កិច្ចពិភាក្សានេះនឹងផ្តោតលើសារៈសំខាន់នៃការចូលរួមរបស់កម្មករ ដើម្បីជំរុញការកែលម្អប្រកបដោយនិរន្តរភាព។ វាគ្មិនកិត្តិយសមកពីប្រទេសជាច្រើននឹងចែករំលែកអំពីការអនុវត្តដែលទទួលបានជោគជ័យ និងទ្រឹស្តីមួយចំនួនស្តីពីការជំរុញការកែលម្អ។ ការស្វែងយល់ពីភាគីពាក់ព័ន្ធក្នុងស្រុកនឹងបង្ហាញពីវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការកសាងឧស្សាហកម្មដែលមានទំនួលខុសត្រូវ និងប្រកបដោយបរិយាប័ណ្ណ។ |
| ១២:៤៥– ០២:០០ | ពិសារអាហារថ្ងៃត្រង់ |
| ០២:០០– ០៣:០០ | វគ្គពិភាក្សាក្រុមតូចៗអំពីដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដើម្បីគៀងគរការចូលរួមកម្លាំងពលកម្ម |
| | ក្រុមទី ១ នឹងពិភាក្សាស្វែងរកវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្កើនការចូលរួមរបស់កម្មករ។ កិច្ចពិភាក្សានឹងបង្ហាញពីឧបករណ៍ និងវិធី |

| | |
|---|---|
| | សាស្ត្រដែលទទួលបានជោគជ័យដោយផ្តោតលើរបៀបដោះស្រាយដែលអាចជំរុញឱ្យមានការចូលរួមកាន់តែខ្លាំងរបស់កម្មករនៅក្នុងឧស្សាហកម្មវាយនភ័ណ្ឌ។ |
| ០២:០០– ០៣:០០ | វគ្គពិភាក្សាក្រុមតូចៗអំពីរបៀបធ្វើការជាមួយកម្មករនៅកម្រិតមូលដ្ឋាន |
| | ក្រុមទី ២ នឹងពិភាក្សាដោយផ្តោតលើតួនាទីរបស់អង្គការដែលគាំទ្រសំឡេងកម្មករស្ត្រីនៅក្នុងវិស័យវាយនភណ្ឌ (ឧទាហរណ៍ អង្គការតំណាងស្ត្រី អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ណផ្សេងៗទៀត)។ ការពិភាក្សានឹងស្វែងរកយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព និងវិធីសាស្រ្តអនុវត្តន៍ជាក់ស្តែង ដែលអង្គការទាំងនេះបានបង្កើតឡើង ដើម្បីផ្តល់សិទ្ធិអំណាច និងលើកទឹកចិត្តដល់កម្មករ ឆ្ពោះទៅរកការកសាងកម្លាំងពលកម្មនិងផលិតភាពការងារប្រកបដោយបរិយាប័ណ្ណ។ |
| ០៣:០០– ០៤:០០ | សម្រាកអាហារសម្រន់ |
| ០៤:០០– ០៥:០០ | កិច្ចពិភាក្សាស្តីពីភាពជាដៃគូសម្រាប់គាំទ្រដល់ការចូលរួមរបស់កម្មករក្នុងឧស្សាហកម្មវាយនភណ្ឌ |
| | កិច្ចពិភាក្សានេះនឹងផ្តោតលើតួនាទីនៃកិច្ចសហប្រតិបត្តិការក្នុងចំណោមតួអង្គសំខាន់ៗនៅក្នុងវិស័យនេះ រួមមាន អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងតួអង្គឧស្សាហកម្ម។ ការពិភាក្សានឹងបង្ហាញពីភាពជាគំរូនៃដៃគូដែលទទួលបានជោគជ័យ ចែករំលែកការយល់ដឹងអំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងស្វែងរកឱកាសដើម្បីពង្រីកសកម្មភាពគំនិតផ្តួចផ្តើមទាំងនេះតាមតំបន់។ |
| ០៥:០០ | បិទកម្មវិធី |
| | ការឆ្លុះបញ្ចាំងអំពីការយល់ដឹង និងសារសំខាន់ៗដែលទទួលបានពីសិក្ខាសាលានិងបិទកម្មវិធី។ |

របៀបវារៈថ្ងៃព្រហស្បត្តិ៍ ទី២៧ ខែ កុម្ភៈ – ផ្នែក ខ

| ពេលវេលា | ការអភិវឌ្ឍន៍អាជីវកម្មសម្រាប់សេវាកម្មប្រកបដោយនិរន្តរភាព<br>ច្បាប់កំពុងជំរុញឱ្យមាននិរន្តរភាព ហើយតម្រូវការច្បាប់ទាំងនោះកំពុងស្ថិតក្នុងការផ្លាស់ប្តូរ។ បណ្តាញនៃស្ថាប័នជាច្រើន ធ្វើការដើម្បីគាំទ្រការផ្លាស់ប្តូរនេះតាមរយៈការអភិវឌ្ឍន៍សេវាកម្មអាជីវកម្មដោយយកចិត្តទុកដាក់និងគិតគូរអំពីនិរន្តរភាព។ ចូលរួមការពិភាក្សាដើម្បីស្វែងយល់អំពីតម្រូវការនៃការផ្លាស់ប្តូរនៅក្នុងវិស័យនេះ។ |
|---|---|
| ០៨:៣០– ០៨:៥០ | បើកកម្មវិធី |
| | លោក Martin Brisson, នាយកប្រតិបត្តិ, សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា<br>លោក Marc Beckmann, នាយកគម្រោង, GIZ FABRIC |
| ០៨:៥០-០៩:៣០ | ការណែនាំនិងការធ្វើបទបង្ហាញអំពីស្ថាប័នធុរកិច្ចអ៊ឺរ៉ុប (EOBs) និងបណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH) |
| ០៩:៣០-១០:៣០ | កាផ្តល់ធាតុចូល |
| | - អនាគតនៃនិរន្តរភាពក្នុងឧស្សាហកម្មវាយនភ័ណ្ឌ<br>- ទម្រង់ទិសអំពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន (HREDD) |
| ១០:៣០-១០:៥០ | សម្រាកអាហារសម្រន់ |
| ១០:៥០- ១១:៤០ | ការចែករំលែកអំពីរឿងរ៉ាវជោគជ័យទាក់ទងនឹងនិរន្តរភាព |
| | តំណាង EBO |
| ១១:៤០-០១:៣០ | សម្រាក់អាហារថ្ងៃត្រង់ |
| ០១:៣០-០៥:០០ | សិក្ខាសាលា |
| | អ្នកចូលរួមនឹងពិនិត្យមើលឡើងវិញអំពីផែនការសកម្មភាពអំពីនិរន្តរភាពដែលបានអនុវត្តន៍ពីមុន ចែករំលែកការអនុវត្តល្អបំផុត និងការបែកចែកជាក្រុមតូចៗ៖<br>- ការលើកកម្ពស់សមភាពយេនឌ័រនៅកន្លែងការងារ<br>- ការកសាងកិច្ចសហប្រតិបត្តិការសម្រាប់អនាគតបៃតង<br>- ការគាំទ្រភាពជាដៃគូឯកជន-សាធារណៈលើនិរន្តរភាព |
| ០៥:០០ | បិទកម្មវិធី |
| | លោក Zandre Van Straten, អ្នកសម្របសម្រួលផ្នែកសេវាកម្ម, សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា |